# ការសំម្ភាសន៍របស់អ៊ុំ អាន សិង៉ាម

ក៖ អ្នកសំម្ភាសន៍គេមាន រត្ន ស្រីភាព ខ៖ អ្នកដែលត្រូវបានគេសំម្ភាសន៍ អានសិង៉ាម

## ជីវប្រវត្តិសង្ខេបរបស់អុំស្រី អាន សិង៉ាម

ក៖

គាត់ជាអ្នកដែលបានជួយនឹងជិវិតនឹងពិបាកហើយគាត់នឹងមិនបានសប្បាយចត្តិប៉ុន្មានទេនៅក្នុងជិវិតគាត់នៅពេលដែលគាត់នឹងបានជួបនឹងបុរសម្នាក់គាត់នឹងបានថាល្អហើយតែគាត់បានគិតនឹងខុសគឺប្តីគាត់មិនបានរកស៊ីអីចិញ្ចឹមគាត់ផងហើយថែមទាំងនឹងបានវ៉ាយគាត់ទៀតចឹងគាត់នឹងមិនបានមានសេចក្តីសុខនឹងប៉ុន្មានទេហើយគាត់នឹងក៏បានមានកូនដែលមានបញ្ហាខាងប្រសៃសប្រសាទៀតហើយកូនគាត់នឹងបានដេញវ៉ៃគាត់ទៀតចឹងគាត់មិនបាននឹងមានពេលណាដែលនឹងបានសប្បាយចិត្តសោះហើយរឿងដែលសំខាន់គាត់នឹងបានពិការដៃនឹងមួយជំហៀងទៀតផងគ្រួសារគាត់ទាំងមូលនឹងបានធ្លាប់លើគាត់ទាំងអស់កាលចិញ្ចឹមចៅហើយនឹងកូនដែលបានមានជំងឺប្រសៃសប្រសាទៀតផង។ធ្វើឡើងនៅភូមិតាខ្មៅ ឃុំកោះក្របី ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ធ្វើឡើងនៅថ្ងៃទី ២៨ ខែ ០២ ឆ្នាំ ២០១៨។

ក៖ ជាដំបូងនាងខ្ញុំមានឈ្មោះ រត្ន ស្រីភាព
សុំអនុញ្ញាតិធ្វើការសំម្ភាសន៍ជីវប្រវត្តិអ៊ុំណាអ៊ុំខ្ញុំធ្វើការសម្ភាសន៍ជីវប្រវត្តិអ៊ុំធ្វើឡើងដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថា BYU
ណាអ៊ុំដែលមានទៅតាំងនៅអាមេរិចដើម្បីថែរក្សាជីវប្រវត្តិជីដូនជីតារបស់ពួកយើងទាំងអស់គ្នានឹងជីវិត្តរបស់អ៊ុំថែរក្សាតុកអោយកូនចៅជំនាន់ក្រោយអោយគាត់បានដឹងនឹងបានស្តាប់ថាអ្នកជំនាន់មុននឹងមានការពិបាកអីខ្លះចឹងអ៊ុំចាំចឹងតើអ៊ុំយល់ព្រមអោយខ្ញុំយកសម្លេងអ៊ុំដាក់ចូលក្នុងសាកលវិទ្យាល័យបានទេអ៊ុំ?

ខ៖ ចាំបានតារមិនអីទេ។

ក៖

ចាំហើយខ្ញុំក៏សូមអរគុណអ៊ុំសំរាប់ចំណាយពេលដើម្បីពិភាកសារជាមួយនឹងខ្ញុំហើយនៅពេលសម្ភាសន៍អ៊ុំនឹងគឺខ្ញុំធ្វើឡើងនៅថ្ងៃទី២៨ខែ០២ឆ្នាំ២០១៨ណាអ៊ុំ?

ខ៖  ចាំ!

ក៖  ចាំចឹងអ៊ុំមានឈ្មោះអ្វីដែលអ៊ុំ?

ខ៖  ខ្ញុំមានឈ្មោះថា អាន សិង៉ាម។

ក៖  ចាំចឹងតើអ៊ុំមានឈ្មោះគេហៅខាងក្រៅទេ?

ខ៖  គេបានហៅខ្ញុំថា ង៉ាមៗនឹង។

ក៖
ចាំចឹងអត់មានគេបានហៅឈ្មោះអីផ្សេងទេអ៊ុំចឹងសព្វថ្ងៃនឹងតើអ៊ុំមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖  ខ្ញុំមានអាយុ ៥៧ឆ្នាំហើយ។

ក៖  ចាំអូអ៊ុំនៅចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនអ៊ុំទេ?

ខ៖  ខ្ញុំបានភ្លេចអស់ហើយខ្ញុំនឹងបានវ៉ែងអស់ហើយកាលនឹងខ្ញុំបានកើតនៅឆ្នាំ១៩៥៧។

ក៖  ចាំៗចឹងអ៊ុំបានកើតនៅឆ្នាំ១៩៥៧ហើយសំរាប់អ៊ុំនៅស្រុកកំណើតនៅណាដែលអ៊ុំ?

ខ៖  ខ្ញុំនៅកោះក្របីនៅភូមិតាខ្មៅស្រុកកណ្ដាលស្ទឹងខេត្តកណ្ដាល។

ក៖  ចាំចឹងអ៊ុំនៅខេត្តកណ្ដាល?

ខ៖  ទៅពីរឹកខ្មៅទៅ។

ក៖  ចាំអ៊ុំនៅហួសទៅភូមិតាំហ៊ុនទៀតអ៊ុំ?

ខ៖  អត់ដល់យើងនៅលើនេ៎នឹង។

ក៖  ចឹងអ៊ុំនៅជិតពេញនេ៎នឹងអ៊ុំ?

ខ៖  ចាំខ្ញុំនៅជិតដែលនឹង។

ក៖  ចាំអ៊ុំនៅជិតនឹង?

ខ៖  ចាំ!

កៈ
ចាំចឹងអ៊ុំនៅខេត្តកណ្តាលជិតនឹងខ្ញុំស្មានតែអ៊ុំនឹងនៅតាំហ៊ុនចឹងអ៊ុំមានបងប្អូនបង្កើតនឹងប៉ុន្មាននាក់ដែល?

ខៈ ខ្ញុំនឹងមានប្អូន៥នាក់ស្លាប់អស់ហើយនៅសល់តែស្រីៗ។

កៈ ចឹងទាំងអស់នឹងមាន៨នាក់?

ខៈ បងប្អូនខ្ញុំនឹងមាន៧នាក់។

កៈ ចាំចឹងតើមានប្រុសប៉ុន្មាននាក់ស្រីប៉ុន្មាននាក់ដែលអ៊ុំ?

ខៈ មានប្រុស៣នាក់ស្រី៤នាក់។

កៈ ចាំហើយអ៊ុំជាកូនទីប៉ុន្មានដែលអ៊ុំ?

ខៈ ខ្ញុំជាកូនទី៦បន្តពីកូន៧គេ។

កៈ
អូចឹងអ៊ុំជាកូនទី៦ហើយអ៊ុំអនុញ្ញាតិអោយខ្ញុំបានស្គាល់បានទេថាបងប្អូនអ៊ុំទាំង៧នាក់នឹងគាត់នឹងមានឈ្មោះអីគេខ្លះដែលអ៊ុំ?

ខៈ មិនបាត់ចង់ស្គាល់ទេ។

កៈ
អ៊ុំចឹងខ្ញុំគ្រាន់តែចង់ដឹងថាអ៊ុំនឹងប្អូនប្អូនអ៊ុំនឹងមានឈ្មោះអីខ្លះគ្រាន់ទុកអោយកូនចៅជំនាន់ក្រោយបានស្គាល់ចឹងណាស់អ៊ុំ?

ខៈ អត់អីទេតែបងប្អូនខ្ញុំនឹងគេសិទ្ធតែជាអ្នកគ្រាន់ចឹងមានតែយើងជាអ្នកក្រ។

កៈ ចឹងអត់អីទេអ៊ុំហើយសំរាប់អ៊ុំកាលនៅពីក្មេងតើអ៊ុំចូលចិត្តធ្វើអីជាមួយគ្នាទេអ៊ុំកាលនឹង?

ខៈ
ខ្ញុំនៅពីក្មេងមានបានធ្វើអីទេគ្រាន់ថានៅដាំបាយអោយឪពុកម្តាយនឹងបានហូបកាលនឹងគាត់នឹងដើរទៅព្រៃគរចឹងម្តាយខ្ញុំនៅធ្វើស្រែចំការចឹងជំនាន់គាត់ៗរែងលារការរែងបាញ់បែងលក់ចឹងណា។

កៈ ចាំ!

ខៈ
ដល់អស់ពីភារៈកិច្ចនឹងធ្វើស្រែម្ដាយខ្ញុំនឹងហើយឪពុកខ្ញុំគាត់ដើរកាម៉ាលធ្វើការជាមួយក្មួយគាត់ចឹងទៅជូនកាលគាត់នឹងបានទំនេរគាត់នឹងទៅជួយធ្វើដីស្រែដក់ស្ទូងជាមួយនឹងម្ដាយចឹងទៅ។

កៈ
ចឹងអ៊ុំបាននៅពីក្មេងអ៊ុំគ្រាន់តែជួយបានដាំបាយអោយលោកឪពុកហើយនឹងម្ដាយពិសារចឹងទៅណាអ៊ុំហើយបើសំរាប់អនុស្សាវរីយ៍ជាមួយនឹងបងប្អូនដូចជាដើរចាប់ក្ដាមចាប់ខ្ចងអីនឹងដែលទេអ៊ុំ?

ខៈ ចាំកាលនឹងដែលតើតែជំនាន់អាពត។

កៈ ចឹងអ៊ុំបានធ្វើចឹងដែលតែជំនាន់អាពតកាលនឹងអ៊ុំបានធ្វើអីគេអ៊ុំកាលនឹង?

ខៈ ជំនាន់អាពតនែ៎ជំនាន់អាពតនឹងកាលនឹងគេបានហៅខ្ញុំកងនារី។

កៈ ចាំ!

ខៈ
រួចដល់ពេលឆ្នាំ១៩៧៩គេនឹងបានរៀបចាប់រៀបខ្ញុំឪពុកជំនាន់នឹងគាត់នឹងមិនបានអោយរៀបទេប៉ុន្តែគេនឹងថាមិនអោយកូននឹងគេៗនឹងសម្លាប់អស់មួយពូតហើយខ្ញុំបងប្អូនខ្ញុំនីជុំគ្នាតែ៣នាក់កាលនឹងហើយស្រីៗនឹងបានស្លាប់អស់ហើយ។

កៈ ចាំ!

ខៈ
កាលនឹងបានបែកខ្លះចឹងទៅដូចដល់ហើយទៅក៏បានចាប់អារម្មណ៍ខ្ញុំនឹងថាអត់ទៅខ្ញុំថាខ្លាចចឹងណាដល់ពេលចឹងទៅខ្ញុំនឹងរៀបក្រោយគេ២៧គូនឹងណាប្ដីខ្ញុំកាលនឹងគេនឹងរៀបប្អូនស្រីគេនឹងមួយហើយខ្ញុំនឹងរៀបក្រោយគេនឹងបង្អស់ចឹងកាលនឹងទាំងអស់២៧គូឡើងរៀបដល់រៀបទៅដូចថាយាយអុនរាសីគេនឹងឡើងចឹងកាលនឹងហើយគេនឹងបានមានដល់កំរិតហើយប្ដីគេបានធ្វើនៅខេត្តព្រះវិហារនៅខាងខេត្តនឹងហើយសំរាប់ប្អូនថ្លៃខ្ញុំនឹងក៏គេនៅមានគេចំណែកខ្ញុំប្ដីស្លាប់ខ្ញុំនឹងពិកាលដៃទៀត។

កៈ អ៊ុនឹងបានពិកាលដៃនឹងតាំងពីកំណើតមករឺក៏យ៉ាងណាដែលអ៊ុំ?

ខៈ
អត់ពីកំណើតមកទេខ្ញុំទើបនឹងពិកាលជាង១០ឆ្នាំនឹងទេខ្ញុំនឹងធ្វើការចិញ្ចឹមកូនតូចកាលនឹងចិញ្ចឹមវាដល់ទៅកាលនឹងខ្ញុំនឹងបានគ្រោះថ្នាក់ចរាចរណ៍។

កៈ
អ៊ុំបានគ្រោះថ្នាក់ចរាចរណ៍កាលនឹងជាមូលហេតុអីអ៊ុំកាលនឹងបើកខ្លួនឯងរឺក៏ដោយសារមិចដែលអ៊ុំកាលនឹងសុំទោសដែលខ្ញុំនឹងបានសួរអ៊ុំចឹងអ៊ុំ?

ខៈ កាលនឹងខ្ញុំនឹងបានជិះឡានដឹកសំរាម។

កៈ ចឹងកាលនឹងអ៊ុំបានជិះឡានដឹកសំរាម?

ខៈ មែនទេគេបានហៅឡានជាង១តោនកាលនឹងគេបានហៅឡានអីជាង១តោននឹង។

កៈ ខ្ញុំអត់បានដឹងដែលអ៊ុំតែឡាននឹងគេបានពេះអ៊ុំចឹងកាលនឹងអ៊ុំ?

ខៈ
កាលនឹងខ្ញុំនឹងបានជិះខាងស្តាំដៃដល់ហើយទៅកង់វាមិនជិះខាងឆ្វេងដៃកាលនឹងគេចទៅវារូចខ្លួនដល់ហើយយើងនែកាលនឹងបានក្រពឹតឡាននឹងអស់មួយជំហៀង។

កៈ អូចាំ!

ខៈ
ដល់ហើយទៅគេនឹងបានជួយហើយទៅកាលនឹងគេនឹងបានយកខ្ញុំទៅពេទ្យកាម៉ែតទៅដល់នឹងខ្ញុំនឹងបានប្រាប់គេថាខ្ញុំនឹងអត់ទៅកាម៉ែតទេខ្ញុំនឹងទៅពេទ្យលោកសង្ឃរងព្រោះអីក្មួយខ្ញុំជីដូនមួយខ្ញុំនឹងម៉ែវានឹងជីដូនមួយនឹងបង្កើតដល់ចឹងទៅគេនឹងបានអោយក្មួយខ្ញុំនឹងជាឌឹកទ័រហើយខាងស្រីនឹងគេខាងឆ្មបនៅពេទ្យលោកសង្ឃងនឹងប្រាប់គេចឹងក៏បានទៅវិញចឹងទៅដល់ចូលដល់ពេទ្យនឹងខ្ញុំនឹងបានសម្លប់បាត់ហើយនឹងកាលនឹងខ្ញុំនឹងបានសម្លប់បាត់ហើយគេយកធ្វើអីក៏ខ្ញុំនឹងមិនបានដឹងដែលដល់ពេលខ្ញុំនឹងបានដឹងខ្លួនមកខ្ញុំនឹងបានបាក់ដៃហើយគេនឹងបានកាត់ពិរដងដៃនឹង។

កៈ ចាំចឹងកាលនឹងអ្នកមីងបានកាត់វគ្គមុនត្រឹមណាអ៊ុំ?

ខៈ វគ្គមុននឹងខ្ញុំបានកាត់លើកំភ្លូនដៃ។

កៈ ដល់ពេលឥឡូវនឹងបានកាត់ដល់ខ្លៀក?

ខៈ ១អាទិត្យគេនឹងបានកាត់១អាទិត្យចឹងកាលនឹង។

កៈ ចឹងអ៊ុំកាលនឹងគេបានថាមិចបានជាគាត់នឹងបានត្រូវកាត់ដៃអ៊ុំចឹងកាលនឹង?

ខៈ
កាលនឹងគេនឹងបានកាត់ខ្ញុំនឹងកាលគេនឹងអត់បានដេកទៅកាលនឹងទុកអោយយើងនឹងផ្ការីកចឹងកាលនឹងហើយទុកអោយស្អុយហើយអោយឈាមអាលិនអាល្វងហើយកាលនឹងស្រមោចវានឹងស៊ីហើយដាក់នៅក្រណាត់ខ្មៅនឹងមើលទៅស្នឹតតែស្រមោចចឹងកាលនឹងដល់បានម៉ារអាទិត្យកាលនឹងបានគេនឹងកាត់ម្តងទៀត។

កៈ អ៊ុំមិចចឹងអ៊ុំកាលនឹងទុកអោយស្រមោចស៊ីសិន?

ខៈ អត់ទេកាលនឹងយើងនឹងរូមដូចជាកាលនឹងខ្ញុំនឹងរូម។

កៈ ចឹងដូចជាអ៊ុំបានរូមនឹងយូរពេកចឹងកាលនឹងអ៊ុំ?

ខៈ នឹងហើយកាលនឹងខ្ញុំនឹងបានរូមយូរពេលនឹង។

កៈ ហើយអ៊ុំឈឺកាលនឹងដែលស្រមោចចាំអ៊ុំចឹង?

ខៈ អត់ឈឺទេគ្រាន់តែវានឹងបានចុកចាប់។

កៈ ដល់ពេលវានឹងបានខាំឈឺណាអ៊ុំ?

ខៈ
វាកាលនឹងបានចាប់ដូចជាកាលបំបាត់ទិចៗខ្ញុំនឹងទៅសុំថ្នាំបំបាត់ការចុកចាប់ចឹងកាលនឹងទៅសុំថ្នាំគេនឹងមកលេប។

កៈ ហើយកាលនឹងពេទ្យអត់បានដោះលោងអោយសិនកាលនឹងអ៊ុំ?

ខៈ
លោងកាលនឹងគ្រាន់ថាកាលនឹងព្រឹកឡើងចឹងខ្ញុំនឹងទៅលោងហើយកាលនឹងខ្ញុំនឹងហើយគេនឹងបានលាប់ថ្នាំអោយចឹងដែលដល់ពេលចឹងទៅខ្ញុំនឹងក៏ចុកចាប់ពេលខ្ញុំនៅបានតយៃ១ខែកន្លះខែនឹងបានសុំគេនឹងមកវិញចឹងកាលនឹង។

កៈ ចាំ!

ខៈ ចេញមកខ្ញុំនឹងខ្លាចអត់លុយមើលខ្លួនក៏ខ្ញុំនឹងបានចេញមកចឹងទៅ។

កៈ នឹងហើយអុំ?

ខៈ ចាំ!

កៈ ចឹងអុំអាចប្រាប់ខ្ញុំបានទេថាលោកឪពុកអ្នកម្តាយរបស់អុំមានឈ្មោះអ្វីដែលអុំ?

ខៈ ឪពុកម្តាយខ្ញុំគាត់មានឈ្មោះថា គួ ស្រេងនឹងម្តាយខ្ញុំឪពុកខ្ញុំឈ្មោះ អាង អិន។

កៈ ចាំហើយអុំដែលមានបានចាំថាគាត់នឹងបានកើតឆ្នាំជូត ឆ្លូវ ខាល ថោះ
តើគាត់នឹងបានកើតឆ្នាំអីដែលអុំ?

ខៈ
មិនបានចាំទេខ្ញុំនឹងបានវង់វេងអស់ហើយអត់ចាំពិព្រោះអីគាត់នឹងអាយុនឹងច្រើនហើយ។

កៈ ប៉ុន្តែគាត់នឹងនៅទេអ្នកមីង?

ខៈ គាត់នឹងបានស្លាប់អស់ហើយគាត់នឹងបានស្លាប់យូរហើយ។

កៈ អូសុំទោសផងអុំ?

ខៈ ចាំអត់អីទេប៉ុន្តែម្តាយខ្ញុំគាត់ស្លាប់ជាង៨០ឆ្នាំហើយតាំងពីជំនាន់អាពត។

កៈ
ចឹងលោកឪពុកហើយនឹងអ្នកម្តាយរបស់អុំកាលនឹងគាត់នឹងបានស្លាប់នឹងលក្ខណៈមិនដែលកាលនឹងអត់អីញ៉ាំរឺមួយគេនឹងបានច្រើនធ្វើការងារអីខ្លះបានគាត់នឹងបានស្លាប់កាលនឹង
?

ខៈ
កាលនឹងគាត់នឹងអត់អីទេកាលនឹងគាត់នឹងនីចិញ្ចឹមជ្រូកកាលនឹងដូចថាគាត់នឹងនៅពីសង្គមចឹងកាលនឹងគាត់នៅស្រុកចឹងកាលនឹងគាត់នឹងបានធ្វើឆ្មបចឹងកាលនឹងដូចថាគាត់នឹងជាឆ្មបកាលនឹងមានចេកមាននំអណ្តាតឆ្កែចឹងមានលុបនឹងស្រាលចឹងណាអោយទ្រនុបចឹងជូនគាត់ចឹងទៅដល់ទៅចឹងយើងមានអីហើយកាលនឹងកូនដែលយើងនឹងបានបង្កើតនឹងកូន

អោយគេនឹងដូចថាខុសគ្រូគាត់ចឹងកាលនឹងចឹងកន្លងមកគេនឹងបានអោយគាត់ចឹងកាលនឹង។

ក៖ ចាំចឹងកាលនឹងម្ដាយរបស់អ៊ុំកាលនឹងបានបង្កើតកូនអោយគេចឹងកាលនឹង?

ខ៖ ចាំដល់ចឹងទៅដល់ម្ដាយខ្ញុំនឹងគាត់ចាប់ផ្ដើមឈឺកាលនឹងគាត់នឹងចាបផ្ដើមក្ដៅញាក់ចឹងទៅក៏យកគាត់នឹងទៅពេទ្យកាលនឹងហើយចឹងទៅខ្ញុំនឹងមិនបានឃើញគាត់នឹងបានស្លាប់ទេកាលនឹងដឹងមិចអីមិចទេពីព្រោះជំនាន់នឹងមានតែប្អូនខ្ញុំទេកាលនឹងគេនឹងបាននៅមើលចឹងកាលនឹងគេនឹងបានដឹងគេនៅជែគេមើលគាត់ចឹងកាលនឹងហើយពេលគាត់នឹងបានស្លាប់កាលនឹងខ្ញុំក៏អត់បានដឹងដែលកាលនឹងមិនបានឃើញម្ដាយនឹងមិចអីមិចទេ។

ក៖ អូចឹងកាលអ្នកម្ដាយរបស់អ៊ុំបានស្លាប់នឹងដូចជាអ៊ុំនៅអាយុប៉ុន្មានឆ្នាំដែលអ៊ុំ?

ខ៖ ចាំកាលនឹងខ្ញុំនឹងនៅចាង២០ឆ្នាំកាលនឹងខ្ញុំនឹង។

ក៖ អូចឹងមានន័យថានៅជំនាន់សង្គ្រាមអាពតនឹងអ្នកមីងធំពេញវ័យហើយនឹងកាលនឹងអ៊ុំហើយនឹងអ៊ុំហើយកាលនឹងអ៊ុំបានដឹងអំពីជីវភាពមិចម៉ារឈឺចាប់ចឹងអស់ហើយនឹងអ៊ុំ?

ខ៖ ១៨ ១៩ឆ្នាំទេកាលនឹង។

ក៖ ចឹងកាលនឹងគេបានហៅអ៊ុំជាស្រ្តីជួរមុនហើយអ៊ុំកាលនឹង?

ខ៖ នឹងហើយកាលនឹងខ្ញុំនឹងជាកង់នារីកាលនឹង។

ក៖ ហើយកាលនឹងគេត្រូវអ៊ុំយកទៅស្ទូនដែលកាលនឹងអ៊ុំ?

ខ៖ ចាំកាលនបឹងគេបានអោយខ្ញុំនឹងដល់ស្មុងហើយឪពុកខ្ញុំនឹងគាត់នៅផ្ទះចឹងហើយព្រឹកឡើងចឹងទៅនឹងទៅសុំអង្ករគេនឹង១កំប៉ុងកាលនឹងគេបានអោយអង្ករហើយនឹងអំបិលមកចឹងកាលនឹងហើយជំនាន់នឹងយើងអត់មានអីទេហើយគាតយ់នឹងចេះតៃច្នៃទៅយកមកដាំជំនាំជុំវិញផ្ទះនឹងកាលនឹងគាត់នឹងបានសរមើលទៅហើយគាត់នឹងបានបុកស្លឹកគ្រៃបុកម្ទេងនឹងលៀងគ្នាចឹងទៅជូនណាគាត់នឹងទៅសុំក្របហុកបាននឹងកាលនឹងយកមកធ្វើហើយយកអីចឹងទៅហើយគាត់ធ្វើច្នៃខ្លួនគាត់កាលនឹងហើយកាលនឹងគាត់នឹងពិងពើមកាលនឹងគាត់បាន

ទៅរៀបក្រមផងហើយពួកខ្ញុំកាលនឹងបានទៅច្រលាច់ចឹងកាលដឹងកំសត់ណាស់កាលជំនាន់នឹងហើយដល់ពេលខ្ញុំនឹងបានរៀបអាពតនឹងក៏បានរៀបហើយចឹងទៅក៏ខ្ញុំនឹងមិនទាន់បានរស់នៅជាមួយគ្នាដែលកាលនឹងគាត់នឹងនៅស្រែហើយខ្ញុំនឹងនៅភូមិពីព្រោះអីខ្ញុំថារៀបនឹងមិនមែនខ្ញុំរៀបដើម្បីអីទេគឺខ្ញុំបានរៀបនឹងកុំអោយគេនឹងសម្លាប់ខ្ញុំនឹងឪពុកម្តាយខ្ញុំហើយនឹងកាលនឹងខ្ញុំនឹងបានរៀបការនឹងគឺដើម្បីអោយសុខសប្បាយនឹងជាមួយគ្នាបងខ្ញុំហើយបងប្អូនចឹងកាលនឹងហើយខ្ញុំទៅកសិដ្ឋានខ្ញុំទៅស្រែនឹងខ្ញុំនឹងដើរទៅចឹងទៅដល់ពេលយប់គេអោយខ្ញុំនឹងដេកនៅនឹងកាលនឹងខ្ញុំនឹងអត់បានដេកនឹងទេខ្ញុំសុខចិត្តរត់មកឪពុកខ្ញុំរត់កាត់វាលហើយនឹងស្រែមានខ្លាចផងហើយមានសត្វអីនឹងយំផងកាលនឹងខ្ញុំនឹងបានរត់ឆ្លងស្ទឹងកាលនឹងដឹងខ្ញុំនឹង។

ក៖ ចាំត្រូវហើយអ៊ុំ?

ខ៖

កាលនឹងខ្ញុំនឹងហែលស្ទឹងកាលនឹងខ្ញុំនឹងមកចឹងកាលនឹងកំសត់ណាស់ខ្ញុំនឹងនិយាយប្រវត្តិនៅជំនាន់អាពត។

ក៖ ចឹងកាលនឹងអ៊ុំបានហែលទឹកមកតែម្តងអ៊ុំស្រី?

ខ៖

នឹងហើយកាលនឹងខ្ញុំនឹងបានហែលទឹកមកចឹងកាលនឹងហែលទឹកឆ្លងមកហើយរត់កាត់វាលស្រែហើយលឺសម្លេងយំនឹងហើយខ្ញុំនឹងបានងៀបរកមើលតែមិនបានឃើញអីទេកាលនឹងខ្ញុំនឹងលឺយំក្រោយខ្នងយើងចឹងកាលនឹងហើយជួនកាលដើរធ្លាក់ព្រូកក្នុងស្រែចឹងកាលនឹង។

ក៖ អូចឹងដើម្បីមកដល់ឪពុកកាលនឹង?

ខ៖

បើកាលនឹងខ្ញុំនឹងមិនមកទេឪពុកខ្ញុំនឹងគាត់អង្គុយចាំមើលកូនដល់យើងនឹងបានស្រែងប៉ាខ្ញុំមកហើយអូណាស់លឺស្រេកប្រាប់ថាមកចឹងកូនមុតទឹកទៅកូនហើយហូបបាយពីរនាក់គាត់ហើយខ្ញុំនឹងចិញ្ចឹមប្អូនធម៌មួយអាវាបាន៤

១០ឆ្នាំហើយដែលខ្ញុំបានចិញ្ចឹមវានឹងដល់ពេលបែកអាពតនឹងវាបានធ្វើទាហានកាលនឹងអូអាកាំភ្លើងវែងពីធំផងនឹងដល់ចឹងទៅខ្ញុំនឹងបានទំនង់កូនខ្ញុំអាបងនឹងបានជួបគ្នាបែកអាពតមកកាលនឹងបានខ្ញុំនឹងរស់នៅជាមួយកាលនឹងខ្ញុំបានចាញ់នៅនឹងនៅឡើងទេហើយកាល

នឹងគ្រួសារខ្ញុំបានទៅរៀននៅវៀតណាមបាន៣ខែដល់គេនឹងមកវិញនឹងគេបានធ្វើនគរបាលកាលនឹងជាស៊ីមយំពាក់អោយកាលនឹងហើយគេនឹងបានអោយកង់៣កាលនឹងគេបានហៅអាកង់៣ៗដល់ចឹងទៅប៉ាខ្ញុំនឹងបានអោយខ្ញុំនឹងមករស់នៅស្រុកកាលនឹងវិញចឹងខ្ញុំនឹងមកនៅវិញហើយប្អូនធម៍នឹងវាកាលនឹងធ្វើទាហាននឹងមិតវាពឹងច្រៀងកាលនឹងហើយដល់ចឹងទៅវានឹងមកធ្វើអ្នកចំរៀងវិញហើយមិនបានដឹងថាវានឹងទៅណាស្លាប់ហើយក៏អីកាលនឹងខ្ញុំអត់ដឹង។

ក៖
ចឹងអ៊ុំបានដាច់ខ្សែរយះចឹងទៅណាអីចឹងអ៊ុំចាំបានទេថាអ្នកម្តាយនឹងលោកឪពុកកាលនឹងគាត់បាននៅពីក្មេងកាលនឹងតើគាត់នឹងបានប្រកបមុខរបរអ្វីដែលកាលនឹងដែលចិញ្ចឹមអ៊ុំ?

ខ៖
ឪពុកម្តាយខ្ញុំបើឪពុកខ្ញុំកាលនឹងគាត់នឹងបានដើរតាមកាពាលជាមួយគាត់នឹងក្មួយចឹងកាលនឹងក្មួយគាត់នឹងគឺមានហើយម្តាយខ្ញុំនឹងកាត់នឹងបានធ្វើតែស្រែចឹងកាលនឹងដល់ចឹងទៅខ្ញុំនឹងបានចៅខ្ញុំនឹងទៅលេងមុងស្យាយអីចឹងទៅចិញ្ចឹមកូនបងមួយនឹងក៏បានកើតអេដស៍ដែលបានកូនពីរនឹងស្រីមួយហើយនឹងប្រុសមួយនឹងរៀនបានហើយនេះចៅខ្ញុំម្តាយបានស្លាប់ហើយតែនៅឪពុកថាឈើព្រឹកមិញដឹងថាចុកឈើក្រពះអោយថ្នាំទៅអោយគេនឹងទិញថ្នាំអោយចឹងទៅហើយខ្ញុំនឹងបានកោសខ្យល់អោយចឹងកាលនឹងឥឡូវនឹងខ្ញុំនឹងចុកដៃឈឺក្រពះនឹងខ្ញុំនឹងទិញថ្នាំអោយលាបហើយ។

ក៖
ចឹងលោកឪពុករបស់អ៊ុំកាលនឹងអ្នកដែលបានដើរតាមកាពាលជាមួយនឹងក្មួយរបស់គាត់ចឹងអ៊ុំស្រីចុះ

អ៊ុំម្តាយអ៊ុំគាត់អ្នកធ្វើស្រែចឹងអ៊ុំ?

ខ៖
ម្តាយខ្ញុំដល់ខែច្រូតស្រូវកាលនឹងនៅតែស្រូវហើយស្រែកាលនឹងរើសទុកពូជវានឹងយកមកទុកហើយដល់ខែធ្វើចំការនៅតែក្នុងចំការនឹងមិនបានដែលនឹងទៅណាទេកាលនឹងនៅជួយធ្វើស្មៅកាលនឹងហើយកាលនឹងខ្ញុំនឹងនៅជាមួយនឹងគាត់ចឹងកាលនឹងគ្រាន់តែគាត់នឹងបានពឹងធ្វើអីនឹងខ្លះចឹងកាលនឹងខ្ញុំនឹង។

កៈ
ចាំអុំចឹងអ្នកម្ដាយអុំគាត់ជាមនុស្សបែកណាដែលអុំលោកទាំង២នាក់នឹងកាលនឹងដូចជាគាត់នឹងកាចហើយនឹងស្លូតទាំងលោកឪពុកហើយនឹងម្ដាយអុំ?

ខៈ អត់អីទេគាត់នឹងធម្មតាតើ។

កៈ ចឹងកាលនឹងអ្នកម្ដាយអុំហើយនឹងលោកឪពុកកាលនឹងគាត់នឹងបានស្លូតចឹងអុំ?

ខៈ
កាលនឹងម្ដាយខ្ញុំនឹងគាត់នឹងរៀងស្លូតតែឪពុកខ្ញុំនឹងគាត់នឹងរៀងកាចទិចដែលកាលនឹង។

កៈ
អូចឹងកាលនឹងលោកឪពុកអុំគាត់នឹងបានកាចចឹងអុំមកពីគាត់កាលនឹងជាអ្នកធ្វើជាទាហានចឹងកាលនឹងបានជាគាត់នឹងរៀងកាចចឹងតែខ្ញុំបានគិតថាកាត់នឹងមិនបានកាចទេតែគាត់នឹងរៀងច្បាស់ចំពោះកូនចៅគាត់នឹងកាលនឹង?

ខៈ
ចាំនឹងហើយគាត់នឹងកាចតែបើអត់គាត់កាលនឹងខ្ញុំនឹងរៀងខ្លាចដែលនឹងកាលនឹងពូកខ្ញុំកាលនឹងពេលគាត់ចឹងកាលនឹងខ្ញុំនឹងបងៗខ្ញុំកាលនឹងទៅច្រូវស្រូវយកបាយនឹងទៅហូបកាលនឹងគាត់នឹងអត់នៅខ្ញុំបានធ្វើរួចកាលនឹងខ្ញុំនឹងបាននាំគ្នានឹងទៅជិះទូកដល់ពេលបានឃើញគាត់មកវិញចឹងក៏បាននាំគ្នានឹងលិចទ

កៈ ចឹងកាលនឹងអុំបានសប្បាយដែលកាលនឹងអុំ?

ខៈ
ចាំនឹងកាលនឹងខ្ញុំនឹងបានសប្បាយដែលកាលនឹងចឹងទៅខ្ញុំនឹងបានឃើញឪពុកខ្ញុំនឹងមកនាំគ្នាលិចទូកចោយហើយក៏នាំគ្នានឹងរត់ពួនគាត់ចឹងកាលនឹងខ្ញុំនឹងកាលនឹងនៅតូចៗ។

កៈ
អុំមានដែលបានចាំអីខ្លះពីខ្សែរជិវិតគាត់កាលដែលគាត់នឹងបានរស់នៅពីតូចទេអុំកាលនឹង?

ខៈ អត់បានចាំទេកាលនឹង។

កៈ
ចឹងអ៊ុំអត់បានចាំទេអ៊ុំហើយសំរាប់លោកតាហើយនឹងលោកយាយចឹងកាលនឹងអ៊ុំទាំងខាងលោកឪពុកហើយនឹងខាងអ្នកម្ដាយអ៊ុំកាលនឹងតើអ៊ុំដែលបានចាំថាគាត់នឹងមានឈ្មោះអីដែលទេអ៊ុំកាលនឹង?

ខៈ
អត់បានចាំទេនឹងតែខ្ញុំនឹងបានចាំយាយចាងម្ដាយខ្ញុំម្នាក់យាយខ្ញុំខាងម្ដាយខ្ញុំនឹងគាត់នឹងមានឈ្មោះថាយាយគង់។

កៈ
ចឹងលោកយាយដេលមានឈ្មោះថាលោកយាយគង់នឹងតើគាត់នឹងបានរស់នៅណាដែលអ៊ុំ?

ខៈ
គាត់នៅត្រទូសសៀមរាបគាត់នឹងស្លាប់យូរហើយគាត់គាត់នឹងបានរស់នៅសៀមរាបត្រទូលយាយខ្ញុំដែលគាតើនឹងបានស្លាប់នឹងកាលនឹងគាត់នឹងបានស្លាប់នៅជំនាន់អាពតនឹងពេលយើងនឹងទៅជាមួយនឹងគ្នាកាលនឹងគាត់កាលនឹងចាស់ហើយរៀងវ័ងហើយនឹងកាលនឹងយាយខ្ញុំនឹងគាត់នឹងកាលនឹងនៅតែលើកអាទេះគេនឹងកាលនឹងរហូតដល់កុងខ្ញុំនឹងបានយកគាត់នឹងទៅដល់កោះធំកាលនឹងនៅភូមិព្រៃកគី។

កៈ ចឹងកាលនឹងអ៊ុំបានកើទាន់ជំនាន់លោកតាហើយនឹងលោកយាយដែលអ៊ុំកាលនឹង?

ខៈ ចាំកាលនឹងខ្ញុំនឹងបានកើតទាន់តើកាលនឹង។

កៈ តើអ៊ុំបាននៅចាំសាច់រឿងអីទេដែលបាននៅជំនាន់នឹងអ៊ុំ?

ខៈ
កាលនឹងខ្ញុំនឹងមិនបានចាំរឿងអីទេកាលនឹងខ្ញុំនឹងមិនដែលនឹងបានសួរដើរមករឿងទេកាលនឹងនៅតែផ្ទះកាលនឹងនៅតែជំបាយអោយឪពុកខ្ញុំហើយនឹងម្ដាយខ្ញុំកាលនឹងហើយនឹងបងប្អូនខ្ញុំកាលនឹងអោយហូបនឹងកាលនឹងចឹងកាលបានជាខ្ញុំនឹងមិបានដឹងអីខ្លះនឹង។

កៈ ចឹងតើក្រុមគ្រួសាររបស់អ៊ុំពួកគាត់នឹងបានរស់នៅខេត្តកណ្ដាលទាំងអស់គ្នានឹងអ៊ុំ?

ខៈ ចាំ

កៈ ចឹងពីបងប្អូនអ៊ុ៥ ៦នាក់នឹងពួកគាត់នឹងបានរស់នៅណាដែលអ៊ុរាល់ថ្ងៃនឹង?

ខៈ
នៅនឹងនៅខេត្តកណ្តាលនឹងមីងប្អូនខ្ញុំនឹង!ហើយគេនឹងបានហៅភូមិលឿងទៅពីវត្តទៀតទៅហើយកាត់តាមផ្លូវម៉េងស្រេងនឹងគាត់នឹងបានលក់អីវ៉ាន់នៅហើយគេនឹងបានធូរធាទេមិនបានពីបាកដូចជាខ្ញុំទេហើយសំរាប់បងស្រីខ្ញុំវិញគាត់នឹងបានរស់នៅជិតរោងចក្រឈៃគូនឹងហើយគេនឹងបានហៅថាចង់ចង្រ្កាយចាស់ហើយក្រោយមកខ្ញុំនឹងមានបងស្រីខ្ញុំមួយទៀតតែគាត់នឹងបានក្រដូចខ្ញុំចឹងដែលតែគាត់នឹងបានរស់នៅស្វាយរលំ។

កៈ អូចាំអ៊ុំ!

ខៈ
គាត់នឹងបានរស់នៅជិតរោងចក្រហ្វូតស្តាយ៣២ទៀងនឹងបងខ្ញុំនឹងគាត់នឹងបារស់នៅនឹងចឹង។

កៈ ចុះអ៊ុំបានមករស់នៅនឹងចុះភូមិនឹងគរបានហៅភូមិអីដែលរាល់ថ្ងៃនឹង?

ខៈ នឹងនៅភូមិព្រៃកតាគង់។

កៈ ចឹងសង្កាត់អីដែលអ៊ុំ?

ខៈ សង្កាត់ចាក់អង្រែក្រងលើផ្លូវ៦០ម៉ែត។

កៈ ចឹងអ៊ុំបានរស់នៅនឹងគេបានហៅនឹងថាជាផ្លូវ៦០ម៉ែតចឹងអ៊ុំ?

ខៈ នឹងហើយចាងក្រោយនឹងក៏ជាផ្លូវ៦០ម៉ែតដែលចឹងកាលនឹង។

កៈ ចឹងកាលនឹងអ៊ុំមានបងប្អូនអ៊ុំដែលបានរស់នៅខាចក្រៅប្រទេសទេរស់ថ្ងៃនឹងអ៊ុំ?

ខៈ
ខ្ញុំនឹងមានតើតែមិនបានទាក់ទង់គ្នាអីទេខ្ញុំនឹងហើយអ្នកដែលបានរស់នៅស្រុកទេនឹងជាជីដូនមួយនឹងខ្ញុំទេដែលបានរស់នៅស្រុកអាមេរិចនឹងតែគេនឹងមិនបានដែលនឹងបាន ទេមកខ្ញុំផងនឹង។

កៈ ចឹងកាលនឹងបងប្អូនអ៊ុំដែលបានរស់នៅនឹងមានច្រើនដែលអ៊ុំកាលនឹង?

ខ៖
នឹងហើយបងប្អូនខ្ញុំនឹងបានទៅច្រើនដែលនឹងកាលនឹងគេនឹងបានទៅនៅជំនាន់អាពតកាលនឹងបានគេនឹងបានទៅចឹងហើយគេនឹងបានផ្ញើរលុយនឹងអោយខ្ញុំនឹងបានម្តងដែលកាលនឹងមុនខ្ញុំនឹងបានបាក់ដៃកាលនឹងគេនឹងបានអោយខ្ញុំនឹងបងប្អូនខ្ញុំនឹងកាលនឹងម្នាក់បាន៥០$ដែលនឹងទាំងខ្ញុំនឹងបានបងប្អូនខ្ញុំនឹងបាន១៥០$ដែលកាលនឹង។

ក៖ អូអុំនៅអាមេរិចនឹងមួយទាំងមូលអុំ?

ខ៖
អើយនឹងហើយបើយើងនឹងមិនមែនបងប្អូនគេផងនឹងហើយបើមីងប្អូនខ្ញុំនឹងមិនបានទៅពីរេល់នឹងគេផងនឹងទាល់តែបងប្អូនខ្ញុំអីនឹងបានគេនឹងបានទាក់ទង់បើចំណែកបងប្អូនខ្ញុំនឹងស្រោចតែម្តងនឹងមិនបានទៅរកគេអីទេ។

ក៖ ចាំ!

ខ៖ គេនឹងបានអោយក៏យកមិនបានអោយក៏ហី!ហើយខ្ញុំនឹងមិនបាននិយាយហើយនឹង ទេអីទេមិនដែលនឹងបាននិយាយជាមួយនឹងគេផងនឹងខ្ញុំនឹង។

ក៖ ចឹងអុំនឹងមិនបាននិយាយជាមួយនឹងគាត់ផងនឹង?

ខ៖ ចាំ!

ក៖ ចឹងអុំអាចប្រាប់ខ្ញុំបានថាតើស្វាយមីអុំតើគាត់នឹងមានឈ្មោះអីដែលអុំ?

ខ៖ ប្តីខ្ញុំនឹងគាត់នឹងមានឈ្មោះប៊ុន សំកល់។

ក៖ ចាំចឹងកាលនឹងអុំបានរៀបការជាមួយនឹងគាត់នឹងនៅឆ្នាំណាដែលអុំ?

ខ៖
ចាំខ្ញុំនឹងបានរៀលកាលជាមួយនឹងគាត់នឹងតាំងពីអាពតមកម្លេះនឹងកាលនឹងឆ្នាំ១៩៧៩។

ក៖ ចាំចឹងកាលនឹងអុំបានរៀបការជាមួយនឹងប្តីអុំនឹងនៅជំនាន់អាពតនឹងអុំកាលនឹង

ខ៖
កាលនឹងខ្ញុំនឹងបានរៀបការជំនាន់អាពតនឹងបានគេនឹងបានការអោយនឹង២៧គូកាលនឹង។

កៈ
ប៉ុន្តែកាលនឹងអ៊ុំបានការនឹងតើលោកឪពុកហើយនឹងអ្នកម្ដាយអ៊ុំកាលនឹងគាត់នឹងបានចូលរួមទេកាលនឹងអ៊ុំ?

ខៈ កាលនឹងអត់មានទេ។

កៈ ចុះសំរាប់ប្រធានភូមិនឹងបានចូលរួមទេកាលនឹងអ៊ុំ?

ខៈ កាលនឹងគេមនឹងបានអោយភូមិហើយនឹងឃុំនឹងបានមកចូលរួមដែលកាលនឹង។

កៈ
ចឹងកាលនឹងមានប្រធានភូមិនឹងបានចូលរួចដែលចឹងកាលនឹងអ៊ុំហើយបានដឹងថាកាលនឹងអាពតនឹងបានស្សំគ្រំគ្នាអោយចឹងកាលនឹងអ៊ុំ?

ខៈ ចាំនឹងហើយកាលនឹងចឹងនឹងហើយកាលនឹង។

កៈ
ចឹងអ៊ុំអាចប្រាប់ខ្ញុំបានទេថាកាលនឹងអ៊ុំនឹងដែលបានចេះសេរអក្សខ្មែរបានខ្លះទេអ៊ុំកាលនឹង?

ខៈ
ពីមុននឹងខ្ញុំនឹងបានចេះដែលនឹងតែមកដល់ពេលខ្ញុំនឹងបានដាក់ដៃខាងស្ដាំនឹងមកខ្ញុំនឹងក៏មិនបានសេរអក្សទៀតដែលនឹងខ្ញុំនឹង។ៗ

កៈ
ចាំចឹងកាលនឹងអ៊ុំបានចេះសេរអក្សខ្មែរដែលអ៊ុំកាលនឹងហើយកាលនឹងជំនាន់បារាំងចូលមកចឹងកាលនឹងតើអ៊ុំដែលបានចេះនិយាយភាសាបារាំងអីខ្លះទេអ៊ុំកាលនឹង?

ខៈ
កាលនឹងខ្ញុំនឹងបានចេះទិចទួចដែលកាលនឹងពីព្រោះកាលនឹងខ្ញុំនឹងបានរៀនដែលតេមិនបានរៀននឹងបានយូរទេកាលនឹងហើយខ្ញុំនឹងបានអត់មានអ្នកណាដែលនៅដាំបាយអោយម្ដាយខ្ញុំនឹងនៅឆ្នាំ១៩៧៦នឹងគេបានវែងគ្នានៅខាងត្បូងនឹងហើយដល់ទៅម្ដាយខ្ញុំនឹងគាត់នឹងបាននៅដាំបន្លែឯផ្ទះកាលនឹង។

កៈ ចាំ!

ខ៖
ដល់ចឹងទៅអត់មានអ្នកណានៅដាំបាយកាលនឹងខ្ញុំនឹងបានឈប់រៀនមកដាំបាយអោយម្ដាយហើយនឹងបងៗនឹងនៅហូបចឹងទៅកាលនឹង។

ក៖
ចាំអ៊ុំចឹងអាចប្រាប់ខ្ញុំបានទេថាអ៊ុំកាលនឹងបានរៀននៅសាលាបឋមសិក្សាកាលនឹងមានឈ្មោះអីដែលកាលនឹងអ៊ុំ?

ខ៖ កាលនឹងខ្ញុំនឹងបានរៀនតាំងពីសង្គមមកកាលនឹងបានត្រឹមតែថ្នាក់ទី៩ទេកាលនឹង។

ក៖
ចឹងកាលនឹងអ៊ុំនឹងបានរៀនបានត្រឹមថ្នាក់ទី៩ទេកាលនឹងអ៊ុំហើយបើកាលនឹងអ៊ុំអាចចាំទេថាកាលនឹងគេនឹងបានរាប់ថ្នាក់ទី១២ចុះក្រោមចឹងកាលនឹងអ៊ុំ?

ខ៖ ចាំ

ក៖ ចឹងកាលនឹងអ៊ុំបានរៀននឹងត្រឹមតែថ្នាក់ទី៩កាលនឹងអ៊ុំ?

ខ៖ ចាំនឹងហើយ។

ក៖ ចឹងកាលនឹងអ៊ុំដែលបានស៊ីស្នូនដក់ស្នូននឹងអោយគេទេអ៊ុំ?

ខ៖
អារឿងនឹងខ្ញុំនឹងបានធ្វើវានឹងបានឆ្អែតអស់ហើយនឹងខ្ញុំកាលនឹងខ្ញុំនឹងបានធ្វើស្រែអោយគេនៅចាក់អង្កែងនឹងកាលនឹងអាកន្លែងនឹងពីមុននឹងចឹងណាកាលនឹង។

ក៖ ចាំ!

ខ៖
ស្មឹតតែជាដីស្រែទេកាលនឹងអីនឹងកាលនឹងគេនឹងបានម៉ៅគេនឹងអោយធ្វើកាលនឹង១ម៉ឺងចឹងកាលនឹងហើយកាលនឹងខ្ញុំនឹងបានស្នូននឹងកាលនឹងម្នាក់ឯងកាលនឹងវល់ដូចក្រទះលងចឹងកាលនឹងនៅប្ដីហើយនឹងកូនកាលនឹងខ្ញុំនឹងមិនបានដែលធ្វើអោយបងប្អូនខ្ញុំនឹងបានគេអត់ដឹងថាខ្ញុំកាលនឹងបានពិបាកមិចទេកាលនឹងអីមិចទេកាលនឹងហើយខ្ញុំនឹងបានចេះតែធ្វើទៅខ្ញុំនឹងហើយកាលនឹងដីដែលនៅក្រោយសង្កាត់នឹងបានបងស្រីខ្ញុំតែដល់ពេលឥឡូវនឹង

បងខ្ញុំនឹងគាត់នឹងបានចាស់ហើយនៅបឹងចំប៉ុជនឹងនឹងបងស្រីនឹងគឺកូនម្ដាយខ្ញុំទេមិនមែនកូនបងប្អូនខ្ញុំដូចថាម្ដាយជាមួយហើយឪពុកនឹងដោយខ្លួនចឹង។

ក៖ ចាំអុំខ្ញុំនឹងបានយល់ហើយខ្ញុំនឹង?

ក៖
ឥឡូវនឹងគាត់នឹងបានចាស់ហើយគាត់នឹងក៏ជាអ្នកដែលឈឺដែលគាត់គាត់នឹងហើយគាត់នឹងបានផ្លាក់ឈាមរាល់តែអាទិត្យដែលនឹងហើយគាត់នឹងបានដូចរាលខែនឹងគាត់នឹងហើយដល់គាត់នឹងបានទិញផ្ទះកាលនឹងអោយខ្ញុំចឹងកាលនឹងតែនៅក្រោមនោះដែលនឹង។

ក៖ ចាំ!

ខ៖
ដល់ពេលហើយទៅខ្ញុំនឹងបានខ្ជិលចឹងទៅកាលនឹងបានរស់នៅជាមួយនឹងប្ដីហើយនឹងប្រពន្ធខ្ញុំចឹងទៅហើយខ្ញុំនឹងបានរស់នៅជាមួយនឹងបងខ្ញុំនឹងក៏គេនឹងបានលក់ទៅអាផ្ទះដែលបាននៅក្រោយសង្កាតនឹងគេនឹងបានលក់ទៅហើយខ្ញុំនឹងដើរស៊ីស្នូនគេចឹងកាលនឹងនៅក្រោយសង្កាត់នឹងដើរបោកខោរអាវហើយនឹងបានដើរកោរខ្យល់ចឹងកាលនឹងហើយនឹងបានអ៊ុតខោរអាវដែលបានគេនឹងបានលក់អាវគ្រជុះចឹងទៅអូកាលនឹងខារកាបូរចឹងទៅណាកាលនឹងថ្ងៃណានោះខ្ញុំនឹងបានទៅធ្វើប្រហុកអោយគេខ្ញុំនឹងបានជិះហើយបើកាលនឹងខ្ញុំនឹងបាននិយាយជីវះភាពខ្ញុំកាលនឹងបានកំសត់ណាស់ខ្ញុំកាលនឹងខ្ញុំនឹងហើយខ្ញុំនឹងលែងនិយាយហើយកាលនឹងបើខ្ញុំនឹងបានទៅធ្វើប្រហុកកាលនឹងធ្វើអោយគេនឹងរប់តោនកាលនឹងធ្វើហើយកាលនឹងបានផ្លឹងគីឡូចឹងទៅកាលនឹងហើយខ្ញុំនឹងបានដើរទៅធ្វើជាមួយនឹងគេនឹងកាលនឹងគេនឹងបានអោយលុយខ្ញុំហើយពេលខ្លះខ្ញុំនឹងបានអង្ករចឹងទៅចេះតែតស៊ូរចឹងទៅកាលនឹងចិញ្ចឹមកូនហើយនឹងបានចិញ្ចឹមប្ដីទៀតកាលនឹងចឹងកាលនឹងប្ដីខ្ញុំនឹងបានវ៉ៃធ្វើបាកខ្ញុំទៀតកាលនឹងដល់ខ្ញុំបានឆ្អែតប្រវត្តិខ្ញុំពេលឥឡូវខ្ញុំនឹងមិនដែលនឹងគិតប្ដីសីនឹងទេខ្ញុំនឹងតាំងខ្ញុំនឹងនៅមានដៃទាល់តែខ្ញុំនឹងបានអត់ក៏ខ្ញុំនឹងមិនដែលនឹងគិតដែល។

ក៖ ចាំៗអុំ!

ខ៖
ខ្ញុំនឹងបានបែកបានប្រហែកជិតមួយឆ្នាំដែលខ្ញុំនឹងយកកូនពីរនឹងទៅនៅកំពុងសោមដល់នៅរកខ្ញុំអត់បានឃើញប្អូនថ្លៃខ្ញុំដែលគេនឹងបានមានណាគេបងគេនឹងបានទៅរកខ្ញុំកាលនឹងខ្ញុំនឹងបានរត់ពួនរហូតពេលនឹងពេលវាទៅកាលនឹងខ្ញុំនឹងបានត្រលប់មកអត់អោយអាតូច

ដឹងតូចអត់បានទេនែ៎អាងាប់នឹងរកឪវានឹងអត់បានទេឃើញហើយនឹងបានមកវិញពេលវាមកខ្ញុំទៅកាលនឹងខ្ញុំនឹងបាននឹកឃើញឆ្អែតចត្តិរកស៊ីចឹញ៉ឹមវាធ្វើការសំណាង់ចឹញ៉ឹមវាកាលនឹងកាលនឹងខ្ញុំនឹងបានធ្វើការអោយគេនឹងបានតែ៧០០រៀលទេណាកាលនឹងរហូតដល់ខ្ញុំនឹងបានធ្វើការនឹងអោយគេនឹងបានដល់ទៅ៥០០០រៀលកាលនឹងខ្ញុំកាលនឹងបានខ្ញុំឈប់ខ្ញុំនឹងបានធ្វើការសព្វបែកយ៉ាងខ្ញុំកាលនឹងមិនបានសូវដេកបានពួងទេកាលនឹងខ្ញុំនឹងបានទៅធ្វើផ្ទះអោយគេនឹង
នៅចំការមនបានគេនឹងបានអោយអុសអោយបាវសំណាង់អោយធុងព៉េរត្រូមកហើយវាស្ទឹតតែថាយើងនឹងបានទៅដេកជាមួយនឹងប្រុសស្មាយបានៗអីនឹងមក។

កះ អូចឹងគាត់នឹងបានចោតប្រកាន់យើងទៀតអុំ?

ខះ
ទ្រាំខ្ញុំនឹងបានឆ្អែតហើយខ្ញុំបានវ៉ៃខ្ញុំនឹងបានពីរម្តងខ្ញុំនឹងបានឈប់ម៉ងទៅបងខ្ញុំកាលនឹងបានដាក់ ខ សន្យាហើយកាលនឹងខ្ញុំបានឈប់ហើយមិនបាច់បងឯងនឹងដាក់ ខ
សន្យាទៀតទេហើយបើបងឯងដាក់ ខ
សន្យាបងឯងយកវានឹងធ្វើមេអូវានឹងបានខឹងខ្ញុំហើយវាបានបោកអស់ហើយចឹងទៅវានឹងបានលក់ផ្ទះនឹងទិញម៉ូតូកូនខ្ញុំអីនឹងខ្ញុំនឹងបានអត់វើរវល់អីទេ។

កះ ចឹងអើយតាំងពីតូចរហូតមកដល់ធំតើអុំធ្លាក់មានជីវិតផ្លាក់ប្តូរអ្វីខ្លះទេអុំ?

ខះ ចា៎អត់ទេខ្ញុំ។

កះ អត់ទេណាអុំនែ៎?

ខះ ចា៎!ឥឡូវនឹងនៅនឹងមុនដំបូងខ្ញុំនឹងបាននៅតែពីរនាក់កូនពីរនាក់ចៅ។

កះ ចឹងអុំចូលចិត្តញុំាម្ហូបអ្វីខ្លះទៅអុំ?

ខះ ចា៎ ខ្ញុំមិនបានសូវទេរៀងសាច់រៀងអីត្រីនឹងក៏ខ្ញុំនឹងបានហូបរើសដែល។

កះ ចុះបើសិនជារល្បែងប្រជាប្រិយភាពដូចជាបោះឈូង ទាញ់ព្រាត់
ហើយនឹងបានបះអង្គុយលែងល្បែងអ្វីខ្លួហាអុំ?

ខ៖
អូតឡូវនឹងខ្ញុំនឹងស្រោចដើរលេងទៅកំស្កានដើរលេងអុំមិនដែលនឹងបានទៅមិនបានដើរដែលនៅតែផ្ទះនឹង។

ក៖ ចាំចឹងអុំនឹងបាននៅតែផ្ទះនឹងអុំ?

ខ៖ ចាំ ហើយយើងនឹងមានដែណា។

ក៖ តែបើតាំងពីរមកតើអុំចូលចិត្តលេងទេអុំ?

ខ៖ ចូលចិត្តតើ។

ក៖
ចឹងអើយដូចជាអុំអាចប្រាប់ខ្ញុំទិចបានទេថាអើយអុំចូលចិត្តស្តាប់បទចំរៀងឬមួយក៏ការច្រៀងរាំអីអុំចូលចត្តិទេពីក្មេងមកដល់ពេលអុំមិនបានទាន់មានបញ្ហា?

ខ៖
ពីរមុនខ្ញុំនឹងបានចូលចិត្តច្រៀងពីមុនខ្ញុំនឹងបានច្រៀងនៅរៀនចឹងដល់ត្រឹមខ្ញុំនឹងបានដាក់ដៃចឹងខ្ញុំនឹងសប្បាយអីទេខ្ញុំនឹងខ្ញុំដឹងថាខ្ញុំនឹងបានខំរកចិញ្ចឹមថៅចិញ្ចឹមកូនខ្ញុំនឹងទៅរាល់ថ្ងៃនឹងខ្ញុំម៉ារហឹងទឹកលិចដល់លើផ្ទះនឹងនេំបានគេនឹងបានទិញអោយទិញគ្រែអោយអីអោយហើយខ្ញុំនឹងបានជួយអោយគេអោយគេនឹងបាននៅមួយបន្ទុបនឹងទៅបន្ទុបនឹងហើយខ្ញុំនឹងបាននៅមើលកូននឹងអោយគេទៅរកតែបាយហូបនឹងមិនបានផងខ្ញុំនឹងវេនារកតែបាយហូបនឹងមិនបានផងខ្ញុំនឹងដល់ប្អូនប្រុសនឹងមកបានចតខ្ញុំនឹងនៅកាំជណ្តើពីរនាក់ហើយបានប្រហោះឃើញខ្ញុំនឹងពីរនាក់តែអត់ដែលបានឃើញអីនឹងមកផងនឹង។

ក៖ ចាំតើអុំនៅក្នុងគ្រួសាររបស់អុំមានអ្នកណាដែលបានចេះលេងភ្លេងឧបគ្គន៍ដូចជាជីតារនោរ ចាប៉ីអីដែលអុំ?

ខ៖ អត់ទេអតមាន។

ក៖
ចាំចឹងផ្ទះដែលអុំបានរស់នៅជាមួយនឹងនឹងលោកឪពុកហើយនឹងអ្នកម្តាយរបស់អុំរហូតដល់អំតើផ្ទះនឹងអ្វីមិចដែលអុំដែលអុំ?

ខ៖
ផ្ទះនឹងទៀមតែជំនាន់នឹងយើងនឹងច្រើនតែផ្ទះជំនាន់នឹងច្រើនតែទៀមចឹងកាលនឹងនេះនឹង
។

ក៖ ចាំអ៊ុំចឹងកាលនឹងដំបូងនឹងបានធ្វើអំពីអីដែលអ៊ុំកាលនឹង?

ខ៖ សាំស្បៀ។

ក៖ ហើយជញ្ជាំងអីដែលអ៊ុំ?

ខ៖ ជញ្ជាំងនឹងដូចយើងនឹងវាកាលនឹងស្លឹកត្នោត។

ក៖ ជញ្ជាំងផ្ទះអ៊ុំកាលនឹងបានធ្វើស្លឹកត្នោត?

ខ៖ នឹងហើយស្លឹកត្នោត។

ក៖ ហើយរនៀមធ្វើអីដែលអ៊ុំកាលនឹង?

ខ៖ រនៀមអត់ទេកាលនឹងទិញតែគ្រែកាលនឹងយកមកធ្វើចឹងទៅកាលនឹង។

ក៖
អីចឹងកាលនឹងអ៊ុំបានទិញជាគ្រែចឹងកាលនឹងអ៊ុំហើយបានយកមកដាក់ជាមួយនឹងកូនចៅចឹងអ៊ុំនែ៎ចាំហើយអើយអ៊ុំជំនៀងដែលអ៊ុំបានចេះពីក្រុមគ្រួសាររបស់អ៊ុំដូចជាការគូស្គរត្នោតធ្វើជាកន្ទេហើយនឹងជាអ្នកដែលត្បាញធ្វើកន្ទេហើយអ៊ុំដែលបានចេះទេអ៊ុំ?

ខ៖ ប់នៅជំនាន់អាពតនឹងកាលនឹងខ្ញុំនឹងបានចេះធ្វើកន្ទេ។

ក៖ ចឹងកាលនឹងអ៊ុំនឹងបានចេះធ្វើកន្ទេចឹងអ៊ុំ?

ខ៖
ចាំយើងនឹងមានកូនកាំបិតតូចចឹងយើងទៅស្ហូរអាស្លឹកច្រវែងៗនឹងទៅយើងនឹងនេះវាទៅយើងនឹងបានកន្ទេយើងនឹងបានក្រេងអីចឹងទៅដល់មកដល់ឥឡូវនឹងអត់ទេហើយអត់ដែលបានធ្វើអីទេខ្ញុំនឹងបានរស់នៅតែផ្ទះនឹង។

ក៖
ចឹងអើយអ៊ុំអាចប្រាប់ខ្ញុំបានទិចទេថាជីវិតរបស់អ៊ុំកាតដែលបានជួបនឹងការលំបាកជាងគេនឹងនៅពេលណាដែលអ៊ុំ?

ខ៖
ខ្ញុំនឹងលំបាកទឹងខ្ញុំនឹងបានដាក់ដៃនឹងខ្ញុំនឹងបានពិបាកថាជំនាន់អាពតនឹងថាខ្ញុំនឹងបានពិបាកដូចមកដល់ឥឡូវនឹងខ្ញុំនឹងបានពិបាកជាងគេចឹងខ្ញុំនឹង។

ក៖ អូចាំ!

ខ៖
ខ្ញុំនឹងបានមកពិបាកចាប់កូនខ្ញុំនឹងបានប្រសែសប្រសាហើយវានឹងបានដេញវ៉ៃខ្ញុំនឹងបានរត់ពេញនឹងចឹងកាត់កខ្ញុំនឹងក៏មានហើយវានឹងបានចេះនិយាយម៉ាត់ៗហើយជូនកាលប៉ោកសក់ខ្ញុំនឹងទាញ់ចឹងយូរខ្ញុំនឹមិចក៏មានហើយខ្ញុំនឹងអត់នៅជាមួយនឹងអ្នកណាទេរស់នៅជាមួយនឹងបីនាក់នឹងខ្ញុំនឹងចៅខ្ញុំនឹងអាតូចនឹងមិចក៏មាន៣២.៤៨ហើយអាតូចនឹងអោយតែឃើញប៉ាវានឹងវានឹងបានរត់តាំងកូនហើយនឹងឪនឹងហើយតែខ្ញុំនឹងបានពេទ្យគុន្ធាបុផ្ផាហើយគេនឹងបានជួយខ្ញុំនឹងរាល់ខែទឹកដោះគោរាល់ខែអោយវានឹងបានប៉ុន្មានមួយខួរកន្លះដែលកាលនឹងហើយគេនឹងបានអោយហើយខ្ញុំនឹងបានចេះតែអង្វរគេកាលនឹងហើយគេនឹងបានចេះតែអោយចឹងទៅកាលនឹងហើយគេនឹងបានអោយមួយកន្លះ។

ក៖ ចាំចឹងអុំជីវីតអុំនឹងបានជួបនឹងតែបញ្ហានឹងហើយអុំមិនដែលបានសប្បាយចិត្តខ្លះទេអុំ?

ខ៖
ចាំសប្បាយចត្តិថ្ងៃណាខ្លះចឹងទៅខ្ញុំនឹងធ្វើអោយខ្ញុំនឹងបានសើចទៅខ្ញុំនឹងបានសើចចឹងទៅ។

ក៖ អូចាំចឹងថ្ងៃណាពិបាកក៏ពិបាកចឹងទៅអុំ?

ខ៖ ចាំនឹងថ្ងៃណាដែលខ្ញុំនឹងបានពិបាកក៏ពិបាកចឹងទៅ។

ក៖
អូចឹងអុំពិបាកហើយអុំដែលមានបំណាងប្រាថ្នាចង់ធ្វើអីអុំដូចជាកាលដែលអុំបាននៅរៀនចឹងអុំចង់ធ្វើជាគ្រូពេទ្យដូចជាអ្នកគ្រូឬក៏ចង់បានធ្វើជាប៉ូលិសអីចឹងអុំដែលបានចង់ធ្វើទេ?

ខ៖
ខ្ញុំកាលនខ្ញុំនឹងនៅមានដៃមានបំណាងខ្ញុំចង់រៀនកាត់ដេកចឹងធ្វើការនៅក្នុងរោងចក្រដល់ត្រឹមខ្ញុំនឹងបានដាក់ដៃចឹងខ្ញុំនឹងធ្វើអីមិនបានកើតនឹងលែងចង់អីក៏លែងចង់គេនឹងបានហៅ

ទៅដើរលេងបងប្អូនខ្ញុំកាលនឹងទៅលេងសៀមរាមអង្គរហើយក័អត់ទៅដែលកំសោមក៏អត់ទៅដែលអត់ទៅម៉ងអត់ចង់ម៉ង។

ក៖ អ៊ុំមានអីដែលបានផ្ដាំផ្ញើរដល់កូនចៅអ៊ុំទេហើយអោយកូនចៅជំនាន់ក្រោយអ៊ុំ?

ខ៖ ដឹងមានពាក្យអីនឹងមានពាក្យ។

ក៖ អោយគាត់នឹងបានខំព្រឹងរៀនចឹងអី?

ខ៖
ចា៎នឹងហើយអោយខំព្រឹងរៀនអោយតស៊ូរចឹងបំណាងខ្ញុំថាចៅស្រីមួយនេះបើវានឹងបានធំទៅអោយវានឹងបានរៀនខាងសំអាតការចង់នេះនឹងជាងធ្វើសក់នឹងហើយបើប្រុសវិញនឹងមានអីខាងធ្វើសំណាងចឹងទៅហើយអត់មានអីទៀតទេ។

ក៖ ចា៎ចឹងអ៊ុំមានតែពឹងនឹងអ៊ុំ?

ខ៖ ចា៎!

ក៖
ចឹងជាចុងក្រោយខ្ញុំសុំអរគុណអ៊ុំហើយខ្ញុំសុំអោយអ៊ុំនឹងមានសុខភាពនឹងល្អហើយសុំអោយបំណាងអ៊ុំនឹងបានសំរាចហើយសុំអោយអ៊ុំនឹងមានអាយុវែងចឹងអរគុណអ៊ុំជំរាបលាអ៊ុំ។